**ព្រះរាជាណាចក្រកម្ពុជា**

**ក្រុមប្រឹក្សាធម្មនុញ្ញ** **ជាតិ សាសនា ព្រះមហាក្សត្រ**

## បទបញ្ជាផ្ទៃក្នុង នៃ ក្រុមប្រឹក្សាធម្មនុញ្ញ

## ក្រុមប្រឹក្សាធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃ ក្រុមប្រឹក្សាធម្មនុញ្ញ ដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស-រកម-០៤៩៨-០៦ ចុះថ្ងៃទី ១៩ ខែ មិនា ឆ្នាំ ១៩៩៨
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ-បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការកំណត់រយៈពេលបម្រើការងារប្រចាំ សប្តាហ៍របស់មន្ត្រីរាជការស៊ីវិល ក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៨០អនក្រ-បក ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីប្រតិទិនឈប់សម្រាកការងាររបស់មន្ត្រីរាជការ នយោជិក កម្មករ ប្រចាំឆ្នាំ ១៩៩៨។

## សម្រេច

### ប្រការ២៧ស្ទួន បន្ថែមនៅលើបទបញ្ជាផ្ទៃក្នុង នៃក្រុមប្រឹក្សាធម្មនុញ្ញ និងបន្ថែមពាក្យ " វិជ្ជាជីវៈ ឬ មុខរបរ " នៅប្រការ៥ និង លុបពាក្យ "សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ និង " នៅប្រការ៩

**ប្រការមួយ**

**ប្រការ២៧ស្ទួន** :ការដកសមាជិកណាមួយពីក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោមនេះ

១- ប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវជូនដំណឹងទៅសមាជិក ដែលត្រូវដកចេញថាគេមានពេលវេលា១៤ថ្ងៃ ចាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹង ដើម្បីធ្វើសារណាការពារខ្លួន។

២- ផុតរយៈពេលនេះទោះបីសាម៉ីខ្លួន មិនបានផ្ញើសារណាការពារខ្លួនមកក្រុមប្រឹក្សាធម្មនុញ្ញក៏ដោយ ក្រុមប្រឹក្សាធម្មនុញ្ញអាចបើកសវនាការសម្រេចលើករណីរឿងនេះបាន។

ក្នុងពេលសវនាការ សាមីខ្លួនអាចអញ្ជើញមកការពារខ្លួននៅមុខក្រុមប្រឹក្សាធម្មនុញ្ញ ឬ ចាត់តាំងតំណាង ឬ មេធាវីមកការពារខ្លួនក៏បាន។

**ប្រការពីរ**

- ត្រូវបន្ថែមពាក្យ " វិជ្ជាជីវៈ ឬ មុខរបរ " នៅមុខពាក្យក្នុងសកម្មភាពត្រង់ប្រការ៥
- ត្រូវលុបចោលពាក្យ " សមាជិកក្រុមប្រឹក្សាធម្មនុញ្ញនិង " ក្រោយពាក្យមន្ត្រីរាជការត្រង់ប្រការ៩។

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៩៨

**ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ**

**ចាន់ សុក**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន នៃរដ្ឋសភា
- ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី១
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី២
- កាលប្បវត្តិ-ឯកសារ